00942978

E291/2/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jul-2013, 10:54
CMS/CFO: Uch Arun

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| **កែលើឯកសារលេខ៖** | **ERN(s):** | **កាលបរិច្ឆេទ៖** | **ប្រភេទកំណែ៖** |
|---|---|---|---|
| E291/2 | 00941382-00941397 | 30 កក្កដា 2013 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| **មូលហេតុនៃការកែតម្រូវ៖** |
|---|
| មានកំហុសតូចដោយសរសេរខុសនៅលើឯកសារដើម |

| **សេចក្តីលម្អិតនៃការកែតម្រូវ៖** |
|---|
| ប្តូរពី លេខ ១៦ ទៅ ១៧ នៅជើងទំព័រ ១៨ និង ៤៣ នៅ ERN ០០៩៤១៣៨៨ និង ០០៩៤១៣៩៥ ។ |

ភាគីស្នើសុំ៖ក្រុមមេធាវីការពារក្តីលោក នួន ជា ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

00942979



គាត់និយាយថា "ខ្មែរដូចគ្នា" កុំឱ្យប៉ះពាល់សោះ។ នេះជាសំដីរបស់ ប៉ុល ពត។[16](គូសបញ្ជាក់បន្ថែម)

សក្ខីកម្មស្រដៀងគ្នានេះ ត្រូវបានបញ្ជាក់ឡើងវិញដោយសាក្សីរូបនេះ និងសាក្សីជាច្រើនទៀត ក្នុងអំឡុងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។[17] ជាក់ស្តែង កងទ័ពបដិវត្តន៍កម្ពុជាដែលបានចូលរួមក្នុងការជម្លៀសទីក្រុងភ្នំពេញ បានផ្តល់សក្ខីកម្មស៊ីសង្វាក់គ្នាថាទាហានសាធារណរដ្ឋខ្មែរ មិនមានទុក្ខទោសឡើយ នៅពេលពួកគេសុំចុះចាញ់នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ឬមុនឬក្រោយបន្តិច។[18]

11. សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា បានកំណត់ឯកសារភ័ស្តុតាងដែលបានជ្រើសរើសមួយចំនួនតូចដើម្បីគាំទ្រការអះអាងរបស់ខ្លួនអំពីអត្ថិភាពនៃគោលនយោបាយសម្លាប់អតីតទាហាន និងមន្ត្រីរបប លន់ ណុល។ ឯកសារទាំងនេះមួយចំនួន ត្រូវបានពិពណ៌នាដោយសហព្រះរាជអាជ្ញា ក្នុងអំឡុងសវនាការដាក់បង្ហាញឯកសារ ហើយត្រូវបានជំទាស់ភ្លាមៗដោយក្រុមមេធាវីការពារ[19]។ ស្រដៀងគ្នានេះ ឯកសារផ្សេងទៀត ដែលសហចៅក្រមស៊ើបអង្កេតយកមកសំអាង ត្រូវបានពិនិត្យឃើញថាមិនមានលក្ខណៈគ្រប់គ្រាន់ឡើយ។ សហចៅក្រមស៊ើបអង្កេតបានដកស្រង់អត្ថបទសារព័ត៌មានមួយចំនួន ដែលពិពណ៌នាអំពីព័ត៌មានស៊ើបការណ៍របស់សហរដ្ឋ

16. ឯកសារលេខ **E3/24** កំណត់ជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ វីដាម តុន ហៅ ភី ភួន, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៧, ទំព័រ ៥។

17. *សូមមើលឧទាហរណ៍* ឯកសារលេខ **E1/98.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ ("សក្ខីកម្មរបស់ ភី ភួន"), ទំព័រ ៨:២ ដល់ ១០ (ភាសាអង់គ្លេស); ឯកសារលេខ **E1/193.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ("សក្ខីកម្មរបស់ អៀង ផាន") ទំព័រ ៣៦:៩ ដល់ ៤៣:៩, ៦៥:២០ ដល់ ៧១:២០ (ភាសាអង់គ្លេស); ឯកសារលេខ **E1/129.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១២ ("សក្ខីកម្មរបស់ មាស វឿន"), ទំព័រ ៩៧:១ ដល់ ១២ (ភាសាអង់គ្លេស); ឯកសារលេខ **E1/139.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ ("សក្ខីកម្មរបស់ គង់ គីម") ទំព័រ ៥០:១៨ ដល់ ៥:១៣ (ភាសាអង់គ្លេស); ឯកសារលេខ **E1/177.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៣ ("សក្ខីកម្មរបស់ ឆោម សែ"), ទំព័រ ៦៤:១៤ ដល់ ៦៥:១ (ភាសាអង់គ្លេស)។

18. *សូមមើល* ជើងទំព័រ ១៧១៦ *ខាងលើ*។

19. សវនាការឆ្លើយតបទៅនឹងការបង្ហាញឯកសារ, ទំព័រ ៥៣:២២ ដល់ ៧៥:៥។

វុយ រោមអ៊្វ"[41]។ ស៊ុំ ជា បានផ្តល់សក្ខីកម្មថា គាត់ពុំមានភ័ស្តុតាងផ្ទាល់អំពីការសម្លាប់ណាមួយឡើយ[42]។ គង់ គីម, មាស វឿន និង អៀង ផាន អ្នកទាំងអស់នេះបានឆ្លើយផ្ទុយទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដោយផ្ទាល់តែម្តង ដោយពន្យល់ថា ទាហាន លន់ ណុល ដែលបានចុះចាញ់នៅក្នុងវាយប្រយុទ្ធគ្នា បានរួចខ្លួន[43]។ សហព្រះរាជអាជ្ញាអះអាងថា អ៊ុំង ឆាត់ និង លឹម សាត បានឆ្លើយផ្ទុយទៅនឹងផ្នែកជាច្រើននៃចម្លើយពីមុនរបស់ពួកគាត់ក្នុងអំឡុងពេលសួរដេញដោល ហើយពិតណាស់មិនមាននរណាម្នាក់ក្នុងចំណោមពួកគាត់នេះបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែកឡើយ[44]។ គ្រប់សាក្សីផ្សេងៗទៀតដែលមានឈ្មោះនៅក្នុងបញ្ជីឧបសម្ព័ន្ធ ក ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ បានផ្តល់សក្ខីកម្មស្រដៀងៗគ្នាថា ពួកគាត់បានឮ ឬបានសន្និដ្ឋានថា មន្ត្រី ឬទាហាន លន់ ណុល ត្រូវបានសម្លាប់។ គ្មាននរណាម្នាក់បានឃើញការសម្លាប់ណាមួយដោយខ្លួនឯងផ្ទាល់ឡើយ។

## គ. សាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា ត្រូវតែប្រឈមនឹងការសួរដេញដោល

21. ដោយពិចារណាទៅលើការរៀបរាប់ពីខាងលើ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា មកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ ភ័ស្តុតាងដែលសាក្សីទាំងនេះផ្តល់ជូន មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការចោទប្រកាន់អំពីអត្ថិភាពនៃគោលនយោបាយក្នុងការសម្លាប់មន្ត្រី និងទាហាន លន់ ណុល។ ភ័ស្តុតាងនោះគឺមានសភាពមិនគួរឱ្យជឿជាក់បានឡើយ និងបានបង្ហាញឱ្យឃើញ ដោយស៊ីសង្វាក់គ្នា នូវភាពកាន់តែមិនគួរឱ្យ

[41] ឯកសារលេខ E-1/148.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ 101:23-102:8 ។

[42] ឯកសារលេខ E-1/140.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី 5 ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ 113:11-22 ។

[43] សូមមើល ជើងទំព័រ ១៧៦៦ ខាងលើ។

[44] សូមមើល ឯកសារ E-291 "សំណើបន្ទាន់ស្នើសុំកោះហៅសាក្សីសំខាន់ៗទាក់ទិននឹងទួលពោធិ៍ជ្រៃ" ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩-១៤។ ឯកសារលេខ **E-1/207.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ 70:15-71:14 ។